# សាកលវិទ្យាល័យអន្តរជាតិនៃប្រទេសជប៉ុន (IUJ) សូមស្វាគមន៍និស្សិតកម្ពុជា

## អំពី IUJ

- IUJ ជាសាកលវិទ្យាល័យមួយរបស់ប្រទេសជប៉ុនដែលបានបង្កើតឡើងនៅឆ្នាំ១៩៨២ ក្នុងបេសកកម្មដើម្បីកសាងអ្នកដឹកនាំនាពេលអនាគត ដែលប្រកបដោយចំណេះដឹងខ្ពស់ទាំងផ្នែកទ្រឹស្តី និងការអនុវត្តន៍ ហើយថែមទាំងចេះស្វែងយល់បន្ថែមនូវវប្បធម៌ផ្សេងៗជុំវិញពិភពលោក ក្នុងទិសដៅដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សង្គមទាំងអស់។
- IUJ ផ្តល់នូវកម្មវិធីសិក្សាថ្នាក់អនុបណ្ឌិតចំនួន៥:
  - អនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្ម MBA
  - អនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្មព័ត៌មានវិទ្យា E-business (កម្មវិធីសិក្សារយៈពេលមួយឆ្នាំ)
  - អនុបណ្ឌិតអភិវឌ្ឍអន្តរជាតិ IDP
  - អនុបណ្ឌិតទំនាក់ទំនងអន្តរជាតិ IRP
  - អនុបណ្ឌិតសិក្សាសន្តិភាពអន្តរជាតិ IPSP
- សាស្ត្រាចារ្យទាំងអស់សុទ្ធតែមានសមត្ថភាពខ្ពស់ ដែលក្នុងនោះ ៩០%មានសញ្ញាប័ត្របណ្ឌិតមកពីសាកលវិទ្យាល័យល្បីៗ នៅសហរដ្ឋអាមេរិកនិងអឺរ៉ុប។ សាស្ត្រាចារ្យទាំងអស់នឹងផ្តល់ជំនួយគ្រប់បែបយ៉ាងដល់ការសិក្សានិងស្រាវជ្រាវរបស់និស្សិត។
- កម្មវិធីប្រឹក្សា និងផ្តល់យោបល់ការងារដែលមានលំនាំបែបអាមេរិក ផ្តល់នូវការបង្ហាត់បង្ហាញ និងបណ្តុះបណ្តាលជំនាញដល់និស្សិតម្នាក់ៗ ដើម្បីទទួលបានអាជីពដ៏ជោគជ័យនាពេលអនាគត។
- IUJ ជាទីកន្លែងប្រមូលផ្តុំគ្នាជុំវិញពិភពលោក ដែលមាននិស្សិតជាង៥០ប្រទេសបានចូលរួម ហើយអតីតនិស្សិតដែលបានបញ្ចប់ការសិក្សាមានចំនួនជាង២៦០០នាក់ ដែលមកពីជាង១០០ប្រទេសទូទាំងសកលលោក។
- កម្មវិធីសិក្សាទាំងអស់បង្រៀនជាភាសាអង់គ្លេស។
- សាកលវិទ្យាល័យមានផ្តល់ជូនកម្មវិធីសិក្សាភាសាជប៉ុនគ្រប់កំរិត។
- មានអាហារូបករណ៍ផ្តល់ជូនបណ្តានិស្សិតមកពីអាស៊ី។

## អំពី កម្ពុជា និង IUJ

- អតីតនិស្សិតកម្ពុជាចំនួន ៣២រូប បានបញ្ចប់ការសិក្សាពី IUJ (១.២% នៃអតីតនិស្សិតបញ្ចប់ការសិក្សាទាំងអស់)
- និស្សិតកម្ពុជាចំនួន៩រូបកំពុងបន្តការសិក្សា (៣.១% នៃនិស្សិតកំពុងសិក្សាទាំងអស់)
- ធនាគារអភិវឌ្ឍន៍អាស៊ី បានឧបត្ថម្ភការប្រកួតតែងសេចក្តីរៀងរាល់ឆ្នាំ។ ប្រធានបទសំរាប់ឆ្នាំ២០០៦ស្តីអំពី "ការអភិវឌ្ឍន៍ជានិរន្តរនៅអាស៊ីនិងប៉ាស៊ីហ្វិក"។ មានតែងសេចក្តីចំនួនជាង៦០០ប្រធានបទត្រូវបានផ្ញើមកពី សាកលវិទ្យាល័យនៃប្រទេសដែលជាសមាជិករបស់ធនាគារអភិវឌ្ឍន៍អាស៊ីចំនួន១៦ ដែលក្នុងនោះមានជ័យលាភីជនជាតិកម្ពុជា២រូបជានិស្សិតមកពី IUJ បានទទួលរង្វាន់ក្នុងចំណោមជ័យលាភីទាំងអស់២៦រូប។ ជ័យលាភីទាំងពីររូបនោះគឺលោក ចាន់ រដ្ឋា និស្សិតថ្នាក់ IRP ឆ្នាំ២០០៧ និងលោក ឡេង ចាន់ប្រាថ្នា និស្សិតថ្នាក់ E-business ឆ្នាំ២០០៧។



ជ័យលាភី IUJ!! រដ្ឋា (ខាងឆ្វេង) និង ប្រាថ្នា

ប្រធានបទរបស់លោករដ្ឋាស្តីអំពី "តើមួយណាសំរាប់អាស៊ាន? ការអភិវឌ្ឍន៍សេដ្ឋកិច្ច ឬ អភិបាលកិច្ចបែបប្រជាធិបតេយ្យ" ចំណែកប្រធានបទរបស់លោកប្រាថ្នាវិញស្តីអំពី "ការលើកតម្កើងបរិស្ថាននិងសេដ្ឋកិច្ចកម្ពុជា"

- លោករដ្ឋាបានមានប្រសាសន៍ដោយឥតមន្ទិលថា "ជោគជ័យរបស់ខ្ញុំបានមកដោយសារ (១) ខ្ញុំបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលភាសាអង់គ្លេសរយៈពេលខ្លីនៅIUJ (២) ខ្ញុំទទួលបានដំបូន្មានទាក់ទងនឹងការសរសេរភាសាអង់គ្លេសពីសាស្ត្រាចារ្យជាច្រើន (៣) ខ្ញុំមានឱកាសប្រើប្រាស់នូវធនធានសិក្សាដ៏សំបូរបែបនៅ IUJ "
- លោកប្រាថ្នាបានមានប្រសាសន៍ថា "ខ្ញុំសប្បាយរីករាយណាស់ដែលបានក្លាយជាជ័យលាភីមួយរូបក្នុងការប្រកួត។ ក្រុមគ្រួសារនិងមិត្តភ័ក្ត្ររបស់ខ្ញុំបានចូលរួមត្រេកអរ ជាមួយជោគជ័យនេះផងដែរ។ ជ័យលាភីទាំងអស់នឹងមកជួបជុំគ្នានៅទីក្រុងក្យូតូនៅខែមិនា ហើយវាជាឱកាសមួយដ៏ល្អសំរាប់ខ្ញុំក្នុងការជួប និងស្គាល់មនុស្សជាច្រើនថែមទៀត។
- សព្វថ្ងៃនេះ លោកប្រាថ្នា គឺជាប្រធាននាយកប្រតិបត្តិក្រុមហ៊ុន Whale Group។ ក្រុមហ៊ុនរបស់លោកមានបំរើសេវាដូចជាការគ្រប់គ្រងកម្មវិធីWhale ការផ្សាយពាណិជ្ជកម្មWhale ការអប់រំWhale និងពេជពុម្ពWhale។
- លោក ហុង សុខហ៊ាង និស្សិតកម្ពុជាដំបូងបង្អស់នៅ IUJ ថ្នាក់ IRP ឆ្នាំ២០០១ កំពុងបំរើការងារជាមួយភ្នាក់ងារអភិវឌ្ឍន៍កាណាដាអន្តរជាតិ (CIDA)។
- លោក ហេង សីហា និស្សិតកម្ពុជាថ្នាក់ IRP ឆ្នាំ២០០៨ ដែលទើបបញ្ចប់ការសិក្សាថ្មីៗនេះ កំពុងបំរើការងារនៅអង្គការ UNDP កម្ពុជា។ លោកត្រូវបានជ្រើសអោយចូលបំរើការងារដោយអតីតនិស្សិត IUJ ថ្នាក់IRP ឆ្នាំ១៩៩៩ បណ្ឌិត Aamir Arain ដែលបានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតនៅប្រទេសអូស្ត្រាលី ហើយដែល

សព្វថ្ងៃកំពុងបំរើការជាប្រធានគំរោងផ្នែកអភិបាល នៅអង្គការ UNDP កម្ពុជា។ លោកសីហាធ្លាប់បានបំរើការងាររយៈពេលខ្លីជាអ្នកសំរបសំរួល និងជាអ្នកបកប្រែ អោយសហគមន៍អឺរ៉ុបប្រតិបត្តិការសង្កេតការបោះឆ្នោតនៅកម្ពុជា សំរាប់សង្កេតការបោះឆ្នោតសភាជាតិឆ្នាំ២០០៨។

- អតីតនិស្សិតកម្ពុជាដែលបញ្ចប់ការសិក្សានៅ IUJ បានបំរើការងារនៅប្រទេសផ្សេងៗក្នុងនោះមាន: កម្ពុជា៧៩.២% អូស្រ្តាលី៨.៣% ជប៉ុន៨.៣% កាណាដា៤.២%។
- អតីតនិស្សិតកម្ពុជាទាំងអស់ ទទួលបាននូវជំនួយផ្នែកហិរញ្ញវត្ថុមកពីបណ្តាម្ចាស់ជំនួយដូចខាងក្រោម:




## សាររបស់អតីតនិស្សិតកម្ពុជានៅ IUJ

*ក្រុមនិស្សិតរបស់ IUJ បង្កើតអោយមាននូវបរិយាកាសដ៏សំបូរបែបផ្នែកវប្បធម៌ ប្រវត្តិសាស្រ្ត សាសនា ជនជាតិ ការសិក្សា និងអាជីព។ ទាក់ទងនឹងអាជីព លោក ហែម វណ្ណី គឺជាគំរូ។ មុនពេលចូលបំរើការងារជាមន្ត្រីសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លោកវណ្ណី បានបើកហាងលក់វត្ថុសិល្បៈនៅផ្ទះលេខ ៥០ ផ្លូវ ៤៣២ ទីក្រុងភ្នំពេញ។*



**លោក ហែម វណ្ណី**
**ថ្នាក់ IDP ឆ្នាំ ២០០២**
**មន្ត្រីសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**ធនាគារអភិវឌ្ឍន៍អាស៊ី**

ហាងលក់វត្ថុសិល្បៈ Sunrise Gallery ត្រូវបានបើកឡើងក្នុងគោលបំណងដើម្បីបង្ហាញពីផ្ទាំងគំនូរដ៏ល្អបំផុតរបស់ខ្មែរ នៅក្នុងបរិយាកាសមួយដែលប្រកបដោយផាសុកភាព ការត្រេកអរ និងការពេញចិត្ត។ ហាងនេះមានលក់រូបគំនូរផ្សេងៗដែលមានគំនូរដែលគូរដោយប្រេង ទឹកពណ៌ ទឹកអាគ្រីលិក ទឹកពណ៌ខាប់ និងគំនូរគូរដោយខ្មៅដៃ។ លើសពីនេះទៀតហាងមានលក់នូវផ្ទាំងគំនូរជាច្រើន ដែលគូរដោយវិចិត្រករល្បីៗដែលលក់ក្នុងតំលៃថេរជូនដល់អតិថិជន។ ផ្ទាំងគំនូរទាំងអស់ត្រូវបានគូរទៅតាមទំហំ និងចំណូលចិត្ត អនុលោមតាមបទដ្ឋានអន្តរជាតិ។
ដោយមានមធ្យោបាយគ្រប់គ្រាន់ យើងបានបង្កើតនូវការតាំងពិព័ណ៌សិល្បៈដ៏សមស្រប។ ផុសចេញពីគំនិតនៃការធ្វើពាណិជ្ជកម្មតាមបែបប្រព័ន្ធព័ត៌មានវិទ្យា ដែលសិក្សានៅក្នុងថ្នាក់ E-business នៅ IUJ យើងនឹងបើកការលក់ដូរតាមប្រព័ន្ធអ៊ីនធើណែត។ ប៉ុន្តែស្ថិតក្នុងដំណាក់កាលដំបូង យើងគ្រាន់តែបង្កើតអោយមានការបញ្ជាទិញទំនិញពីក្រៅប្រទេស ហើយធ្វើការទូទាត់ប្រាក់នៅក្នុងប្រទេស។ ជំហានបន្ទាប់របស់យើងនឹងបង្កើតអោយមានការបញ្ជាទិញទំនិញ និងការទូទាត់ប្រាក់តាមប្រព័ន្ធអ៊ីនធើណែត តាមរយៈគេហទំព័រ www.cam-sunrisegallery.com។ គេហទំព័រនេះ ត្រូវបានបង្កើតដោយមានការជួយជ្រោមជ្រែងពីមិត្តភ័ក្រ្តជនជាតិជប៉ុនជាច្រើនដែលខ្ញុំបានរាប់អាន ហើយដែលខ្ញុំបានទាក់ទងជាញឹកញាប់ដើម្បីជូនដំណឹងពីអ្វី ដែលបានកើតឡើងនៅហាងរបស់ខ្ញុំ។ គេហទំព័ររបស់យើងមានបង្ហាញនូវផ្ទាំងគំនូរសំខាន់ៗជាច្រើន សំរាប់លក់។ ខ្ញុំគិតថា ការធ្វើបែបនេះមិនត្រឹមតែមានលក្ខណៈជាការធ្វើជំនួញប៉ុណ្ណោះទេ ហើយថែមទាំងជាវិធីមួយដែលធ្វើអោយពិភពលោកបានយល់ និងស្ទប់ស្ទែងអំពីស្នាដៃសិល្បៈរបស់វិចិត្រករក្នុងស្រុកទៀតផង។

យើងសូមស្វាគមន៍និស្សិត IUJ ដែលមកទស្សនាហាងរបស់យើងនៅទីក្រុងភ្នំពេញ!



**លោក ចាន់ រដ្ឋា**
**ថ្នាក់ IRP ឆ្នាំ ២០០៧**
**ប្រធានផ្នែកទំនាក់ទំនងសហគមន៍**
**ធនាគារ ANZ Royal**

IUJ ផ្តល់នូវបរិយាកាសសិក្សានិងស្រាវជ្រាវពិសេសជាងគេ ដោយផ្តល់នូវធនធានសិក្សាដ៏សំបូរបែប រួមទាំងមានសាស្រ្តាចារ្យដែលមានសមត្ថភាពខ្ពស់ក្នុងការបណ្តុះបណ្តាល។

សិក្ខាសាលាពិសេសៗ កម្មវិធី PLATFORM ដែលទើបបង្កើត និងកម្មវិធីសិក្សាផ្សេងៗទៀត គឺជាកត្តាដែលផ្តល់ឱកាសអោយនិស្សិតទទួលបានចំណេះដឹងខ្ពស់សំរាប់ការអភិវឌ្ឍន៍សង្គម និងអាជីព។

នៅ IUJ និស្សិតអាចស្វែងយល់ពីវប្បធម៌ដ៏សំបូរបែបមកពីជុំវិញពិភពលោក។ និស្សិតទាំងអស់មិនត្រឹមតែសិក្សាមុខវិជ្ជាជំនាញឯកទេសប៉ុណ្ណោះទេ ហើយថែមទាំងទទួលបាននូវការបណ្តុះបណ្តាលភាសាជប៉ុនដោយឥតគិតថ្លៃថែមទៀតផង។

ចំណុចពិសេសមួយទៀតរបស់ IUJ នោះគឺប្រព័ន្ធសិក្សាចំរុះ ដែលនិស្សិតអាចចុះឈ្មោះសិក្សាគ្រប់មុខវិជ្ជាទាំងអស់ ក្នុងចំណោមកម្មវិធីសិក្សាទាំងប្រាំរបស់សាកលវិទ្យាល័យ ដូច្នេះ ធ្វើអោយនិស្សិតអាចរៀបចំខ្លួនសំរាប់ការងារនាពេលអនាគត។

---